**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីអំពាវនាវ

យោងសេចក្តីជូនដំណឹងលេខ១១៧/២១ សជណ.ច ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់អតីតបុគ្គលិកក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ដែលកំពុងធ្វើការតវ៉ា និយោជក និងសាធារណជន ឱ្យបានជ្រាបថា ការធ្វើសកម្មភាពសម្តែងមតិនាពេលកន្លងមកនេះ គឺជាបាតុកម្មខុសច្បាប់ និងបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិតដែលកំពុងធ្វើការផង ផលប្រយោជន៍និយោជកផង និងសាធារណជនផង។

ក្រសួងសូមធ្វើការអំពាវនាវដល់បងប្អូនដែលកំពុងធ្វើការតវ៉ាឱ្យបញ្ឈប់ការតវ៉ានេះជាបន្ទាន់ និងសូមវិលមកអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីនៃការដោះស្រាយវិវាទការងាររួមវិញ ស្របតាមស្មារតីមាត្រា៣០២ ដល់មាត្រា៣១៧ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ៣១៧សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ដែលបានកំណត់នីតិវិធីបន្ត គឺត្រូវប្តឹងទៅតុលាការ ដើម្បីបញ្ចប់ករណីវិវាទ ក្រោយពេលការផ្សះផ្សា ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងការអនុវត្តវិធានការវិវាទស្របច្បាប់ មិនអាចរកដំណោះស្រាយបាន។

ចំពោះបងប្អូនដែលកំពុងធ្វើការតវ៉ា ដោយលើកមូលហេតុថា និយោជកបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ដល់ខ្លួនមិនត្រឹមត្រូវតាមច្បាប់ សូមបងប្អូនទាក់ទងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈទូរស័ព្ទលេខ ០១២ ៨៧២ ១៦១/០៩២ ៨៨៨ ៥៨៥/០៨៧ ៥២៥ ៦៥៦ ដោយផ្តល់នូវព័ត៌មានអំពីប្រាក់ឈ្នួល ប្រាក់អត្ថប្រយោជន៍ដែលខ្លួនធ្លាប់ទទួលបាន រូបមន្តគណនា និងមូលដ្ឋានគណនា ដើម្បីក្រសួងធ្វើការផ្ទៀងផ្ទាត់ឡើងវិញ។ ក្រសួងនឹងបង្គាប់ឱ្យនិយោជកធ្វើការទូទាត់សំណងបន្ថែមដល់បងប្អូន ក្នុងករណីដែលបងប្អូនបានសហការផ្តល់ព័ត៌មានពេញលេញ ហើយក្រសួងរកឃើញថា និយោជកពិតជាបានគណនាមិនត្រឹមត្រូវតាមច្បាប់ពិតប្រាកដមែន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អតីតបុគ្គលិកដែលកំពុងធ្វើការតវ៉ា និយោជក និងសាធារណជន ជ្រាបជាព័ត៌មាន និងសហការបញ្ចប់ការតវ៉ាខុសច្បាប់នេះ។

*ថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១*

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩